**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣

**តុលាការកំពូល និង មហាអយ្យការ**
**អមតុលាការកំពូល**
លេខ : ....១៦៨/០៨...តកក...

*ភ្នំពេញ, ថ្ងៃទី.០៧...ខែ មេសា ឆ្នាំ ២០០៨*

# ប្រធានតុលាការកំពូល

**ជម្រាបមក**

**ឯកឧត្តមចាងហ្វាងសាលាឧទ្ធរណ៍**

**លោក លោកស្រី ជាប្រធានតុលាការខេត្ត-ក្រុងទាំងអស់**

**កម្មវត្ថុ** : អំពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននូវសាលក្រម ឬសាលដីការដ្ឋប្បវេណី ដែលមិនទាន់ចូលស្ថាពរ។

កន្លងមកតុលាការកំពូលសង្កេតឃើញថា តុលាការខេត្ត-ក្រុងមួយចំនួន ក៏ដូចជាសាលាឧទ្ធរណ៍ដែរ បានចេញសាលក្រម និង សាលដីការដ្ឋប្បវេណី ដែលមានភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ផ្អែកតាមមាត្រា ១៩៦, ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ យោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីសម្រេចដែលប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នមានអានុភាពយកទៅអនុវត្តដូចជាសាលក្រម ឬ សាលដីកាស្ថាពរដែរ ដូចនេះក្នុងការសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ននូវសាលក្រម និង សាលដីការដ្ឋប្បវេណីណាមួយ ចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែមានការពិចារណាឱ្យបានហ្មត់ចត់បំផុត ហើយលុះត្រាតែខ្លួនមានជំនឿមុតមាំថា បើមានបណ្តឹងឧបាស្រ័យចំពោះសេចក្តីសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ននេះ តុលាការជាន់ខ្ពស់មុខជាមិនបដិសេធសេចក្តីសម្រេចរបស់ខ្លួនទេ។

ប្រការដែលគួរឱ្យកត់សំគាល់នោះ គឺថា ការសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ននូវសាលក្រម ឬ សាលដីការដ្ឋប្បវេណីដែលទាក់ទងនឹងការទាមទារសិទ្ធិលើអចលនវត្ថុ មិនត្រូវមានតទៅទៀតទេ សំរាប់ស្ថានភាពបច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលកំពុងតែអនុវត្តយ៉ាងក្តៅគគុកនូវនយោបាយកំណែទម្រង់

ផ្ទះលេខ ២២២, ផ្លូវ ៦៣, សង្កាត់ បឹងកេងកង១ , ខណ្ឌចំការមន ក្រុងភ្នំពេញ, កម្ពុជា. ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១២ ៨២៦
Nº. 222, St. 63, Sangkat beungKengkang I, Khan Chamkarmon, Phnom Penh, Cambodia, Phone/ Fax: (855-23) 212 826

ដីធ្លី ។ ការសម្រេចខុសក្នុងរឿងនេះ ប្រៀបដូចជាការជំរុញឱ្យមានទំនាស់ដីធ្លីកាន់តែកើនឡើង ពីព្រោះថា ភាគីដែលទទួលផលពីការសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ននេះ អាចយកអចលនវត្ថុនោះ ទៅចាត់ចែង ឬ លក់ដូរឱ្យអ្នកផ្សេង ក្នុងពេលដែលរឿងអង្គសេចក្តីមិនទាន់បានសម្រេចជាស្ថាពរ ជាហេតុ ធ្វើឱ្យរឿងក្តីនោះរិតតែស្មុគ្រស្មាញថែមទៀត។

អាស្រ័យហេតុនេះ សូមឯកឧត្តម អស់លោក លោកស្រីទាំងអស់ ជាប្រធាន អនុប្រធាន និង ចៅក្រម នៃសាលាឧទ្ធរណ៍ និង តុលាការខេត្ត-ក្រុង មេត្តាជ្រាប និងអនុវត្តសេចក្តីណែនាំនេះ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ រួមចំណែកក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ។

សូមឯកឧត្តម អស់លោក លោកស្រី មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ។

ប្រធានតុលាការកំពូល

ឌិត មុន្ទី

ផ្ទះលេខ ២២២, ផ្លូវ ៦៣, សង្កាត់ បឹងកេងកង១ , ខ័ណ្ឌចំការមន ក្រុងភ្នំពេញ, កម្ពុជា. ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១២ ៨២៦
Nº. 222, St. 63, Sangkat beungKengkang I, Khan Chamkarmon, Phnom Penh. Cambodia, Phone/ Fax: (855-23) 212 826